ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 551
Date: 03.01.11 Time: 4:10
For : GMAC

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. [illegible] MOC / SM 2010

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនអ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី ដែលជាវិនិយោគិនជាតិ និងបរទេស ប្រធានក្រុមហ៊ុន រោងចក្រ សហគ្រាស ម្ចាស់ផលិតកម្ម អ្នកនាំចេញទាំងអស់ មេត្តាជ្រាបថា កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០កន្លងមកនេះ សហគមន៍អ៊ឺរ៉ុប បានអនុម័តរួចហើយនូវបទបញ្ញាត្តិលេខ (EU) No. 1063/2010 ដែលបានធ្វើវិសោធនកម្ម លើបទបញ្ញត្តិលេខ (ECC) No. 2454/93 ទាក់ទងនឹងវិធានប្រភពដើមទំនិញនាំចូលទៅសហគមន៍អ៊ឺរ៉ុប។ បទបញ្ញត្តិនោះ ត្រូវបានផ្សព្វផ្សាយនៅក្នុងព្រឹត្តិប័ត្រផ្លូវការរបស់សហគមន៍អ៊ឺរ៉ុបកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០។

បទបញ្ញត្តិថ្មីនេះ បានបន្ធូរបន្ថយលក្ខខ័ណ្ឌតម្រូវនានាទាក់ទងនឹងវិធានប្រភពដើមទំនិញ ដែលនាំចេញពីកម្ពុជាក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច។ ការបន្ធូរបន្ថយលក្ខខ័ណ្ឌសំខាន់ៗទាំងនោះរួមមាន:

-ផលិតផលប្រភេទសម្លៀកបំពាក់ភាគច្រើនគឺកម្ពុជាអាចនាំចូលក្រណាត់ពីគ្រប់ប្រទេសទាំងអស់ដើម្បីយកមកផលិតបាន ដោយត្រូវបានទទួលស្គាល់ថា មានប្រភពដើមនៅកម្ពុជា។

-ផលិតផលមួយចំនួនទៀតអាចនាំចូលវត្ថុធាតុដើម ធាតុផ្សំមកពីអាស៊ាន ពីតំបន់ South Asian Association For Regional Cooperation (SAARC) និងពីសាធារណរដ្ឋកូរ៉េ មកផលិតបានដោយគិតដូចធាតុផ្សំក្នុងស្រុករបស់កម្ពុជាផងដែរ។

-ផលិតផលសំខាន់ៗមួយចំនួនទៀត ដូចជាកង់ គឺអាចអនុញ្ញាតឲ្យយកធាតុផ្សំពីក្រៅតំបន់មកផលិតបានរហូតដល់៧០% នៃតម្លៃផលិតផលសម្រេច។

ក្រៅពីចំណុចសំខាន់ៗ ដូចបានជម្រាប់ជូនខាងលើ សូមអ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី ដែលជាវិនិយោគិន ប្រធានក្រុមហ៊ុន រោងចក្រ សហគ្រាស ម្ចាស់ផលិតកម្ម អ្នកនាំចេញ មេត្តាជ្រាបថា មានផលិតផលដែលនាំចេញពីកម្ពុជាច្រើនមុខទៀតក៏អាចទទួលអត្ថប្រយោជន៍ដ៏ច្រើនសន្ធឹកសន្ធាប់ពីការធ្វើវិសោធនកម្ម បទបញ្ញត្តិនេះដែរ។ បទបញ្ញត្តិនេះ នឹងចាប់ផ្តើមអនុវត្តនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ខាងមុខនេះ ។

ដើម្បីជាវិភាគទានសម្រាប់ការសិក្សាលំអិតបន្ថែមទៀតក្រសួងពាណិជ្ជកម្ម សូមជូនភ្ជាប់បទបញ្ញាត្តិនេះជាភាសាអង់គ្លេស ហើយក្រសួងពាណិជ្ជកម្ម នឹងធ្វើការបកប្រែក្រៅផ្លូវការទៅជាភាសាខ្មែរ ព្រមទាំងបោះផ្សាយនៅក្នុងព្រឹត្តិប័ត្រក្រសួងពាណិជ្ជកម្ម នៅពេលខាងមុខនេះ។ បទបញ្ញត្តិនេះអាចរកបាននៅក្នុងគេហទំព័រដូចតទៅនេះ "http://eur-lex.europa.eu/"

អាស្រ័យដូចបានជូនដំណឹងខាងលើ សូមអ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី ដែលជាវិនិយោគិន ប្រធានក្រុមហ៊ុន រោងចក្រ សហគ្រាស ម្ចាស់ផលិតកម្ម អ្នកនាំចេញមេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន:**
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ ម៉ែន សំអន
-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងស្ថាប័ន ខេត្ត-រាជធានី
-សមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា
-រោងចក្រ សហគ្រាស និងក្រុមហ៊ុនទាំងអស់
-ឯកសារ-កាលប្បវត្តិ